# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា
(IBEC) Project

ខែ មេសា ឆ្នាំ ២០១២ លេខ ៩


## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### លទ្ធផលសម្រេចបាន

- សម្រាប់ការចាប់ផ្តើមក្នុងឆ្នាំទី៣ នេះមានកុមារចំនួន ១២៩,៣៧៣ ត្រូវបានជួយគាំទ្រដោយគម្រោង
- ចំនួនសិស្សទទួលអាហារូបករណ៍ក្នុងឆ្នាំទី៣ ៖ បឋមសិក្សាចំនួន ៤,១៧១នាក់ មធ្យមសិក្សាចំនួន ១,៩៣៤នាក់ និងអាហារូបករណ៍គរុសិស្សចំនួន ៣៦០នាក់
- ថវិកាអនុម័តសម្រាប់អំណោយសាលារៀនសរុបចំនួន ២៩០,៨៥០ ដុល្លាសហរដ្ឋអាមេរិក

### ដៃគូគម្រោង IBEC

- គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

  គម្រោងត្រូវប្រតិបត្តិ ដោយអង្គការ អប់រំពិភពលោក ដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។
- ដៃគូក្នុងស្រុកផ្សេងទៀត មានអង្គការ ៖ WCRD, BSDA, NEP និង EDA
- ដៃគូអន្តរជាតិមានអង្គការ ៖ Equal Access និង AIR

## គម្រោង IBEC ឆ្នាំទី៣ចាប់ផ្តើមដោយទទួលបានលទ្ធផលផ្លែផ្កា

### ការស្វែងរកមតិគាំទ្រកម្មវិធីបំណិនជីវិត និងការផ្សព្វផ្សាយ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងត្រីមាសនេះ

ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១២ ជាថ្ងៃចាប់ផ្តើមគម្រោង IBEC ឆ្នាំទី៣ ហើយក៏ជាថ្ងៃដែលបរវេសនកាលថ្មីបានចាប់ផ្តើមផងដែរ ។ គម្រោងក៏បានចាប់ផ្តើមអនុវត្តទៅតាមផែនការដែលសាលារៀនបានធ្វើរួចរាល់កាលពីចុងឆ្នាំមុនដើម្បីឲ្យចំណេញពេលវេលា ។ សមាសភាគទាំង៤របស់ IBEC បានរាយការណ៍ថា ៩២% នៃសកម្ម ភាពចំនួន ២៣៣ដែលបានអនុវត្តអំឡុងពេលត្រីមាននេះ ត្រូវបានបញ្ចប់មួយចំនួន និងមួយចំនួនទៀតកំពុងដំណើរការ ។ ចំពោះសកម្មភាពសំខាន់ៗដែលបានបញ្ចប់យ៉ាងឆាប់រហ័សនោះធ្វើឲ្យ IBEC និងដៃគូរដ្ឋាភិបាលរបស់ខ្លួនមានពេលវេលាច្រើនដើម្បីផ្តោតទៅលើការអនុវត្តសាកល្បងកម្មវិធីអប់រំបំណិនជីវិត ដែលជាកម្មវិធីសំខាន់របស់ IBEC ។ គ្រប់សកម្មភាពដែលរៀបចំសម្រាប់កម្មវិធីសាកល្បងនេះត្រូវបានបញ្ចប់ក្នុងអំឡុងត្រីមាសនេះរួមទាំងការរៀបចំនូវទម្រង់វាយតម្លៃ ការបោះពុម្ព និងចែកចាយនូវសម្ភារៈបំណិនជីវិត (សៀវភៅមេរៀន ផ្ទាំងប៉ូស្ទ័រ ឯកសារសិស្ស) និងសិក្ខាសាលាតម្រង់ទិសដល់ដៃគូរដ្ឋាភិបាល ។

IBEC បានប្រឹងប្រែងបន្តស្វែងរកមតិគាំទ្រ និងការផ្សព្វផ្សាយលើកម្មវិធីបំណិនជីវិតពីរដ្ឋាភិបាល និងសហគមន៍អង្គការក្នុងស្រុកតាមរយៈបណ្តាញផ្សេងៗ ។ អំឡុងពេលដើមត្រីមាសនេះអនុប្រធានគម្រោង IBEC ទទួលបន្ទុកកម្មវិធីបំណិនជីវិត លោក អេង សុខត្រូវបានអញ្ជើញដោយវិទ្យុអាស៊ីអាគ្នេយ៍ដើម្បីចូលរួមក្នុងកម្មវិធីសំណួរចម្លើយទាក់ទងនឹងកម្មវិធីបំណិនជីវិតដែលធ្វើការផ្សាយបន្តផ្ទាល់ ដើម្បីផ្សព្វផ្សាយព័ត៌មានទៅកាន់គ្រប់អ្នកពាក់ព័ន្ធអំពីគោលនយោបាយកម្មវិធីបំណិនជីវិតរបស់រដ្ឋាភិបាល គោលការណ៍ណែនាំ និងគោលការណ៍អនុវត្តសម្រាប់កម្មវិធីបំណិនជីវិតតាមមូលដ្ឋានក្នុងប្រទេសកម្ពុជា និងបញ្ហាដែលបានជួបប្រទះដោយអ្នកអនុវត្ត ។ ក្នុងពេលធ្វើកម្មវិធីសំណួរចម្លើយនោះមានមិត្តអ្នកស្តាប់ជាច្រើនបានទូរស័ព្ទមកដើម្បីបញ្ជាក់ឲ្យច្បាស់អំពីគោលនយោបាយ និងថាតើ USAID-IBEC ជួយក្រសួងយ៉ាងដូចម្តេចក្នុងការអនុវត្តគោលនយោបាយនេះ ។ ជំនួសឲ្យ IBEC អ្នកអត្ថាធិប្បាយក្នុងកម្មវិធីវិទ្យុក៏បានបញ្ចូលអ្នកតំណាងមកពី NEP ផងដែរ ។




នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ២០១២ IBEC ត្រូវបានអញ្ជើញឲ្យចូលរួមដើម្បីចែករំលែកព័ត៌មានអំពីកម្មវិធីបំណិនជីវិតជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាលក្នុងកិច្ចប្រជុំដ៏សំខាន់មួយនៅនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ដែលមានទីតាំងក្នុងក្រសួងអប់រំ ។ ប្រធានគម្រោង IBEC លោក Kurt Bredenberg និងអនុប្រធានគម្រោងទទួលបន្ទុកកម្មវិធីបំណិនជីវិតលោក អេង សុខ បានដឹកនាំការធ្វើបទបង្ហាញទៅលើការសាកល្បងកម្មវិធីបំណិនជីវិតរបស់ IBEC ដែលបានចាប់ផ្តើមអនុវត្តក្នុងខែ វិច្ឆិកា ឆ្នាំ២០១២ ។ បទបង្ហាញបាននិយាយអំពីសាវតាក្នុងការសាកល្បង លទ្ធផលពីការសាកល្បងលើកដំបូងក្នុងឆ្នាំមុន និងពីរបៀបថាតើគួរអនុវត្តកម្មវិធីសាកល្បងនេះយ៉ាងដូចម្តេចក្នុងឆ្នាំទី៣ ។

កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម ណាត ប៊ុនរឿន និងមានអ្នកចូលរួមប្រហែល៤០នាក់ដែលមកពីនាយកដ្ឋានផ្សេងៗ (រួមទាំងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា) ក៏ដូចជាតំណាងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗជាច្រើនទៀត ។ វាជាការលើកទឹកចិត្តផងដែរ ដោយក្រសួងអប់រំជាថ្មីម្តងទៀតបានធ្វើការគាំទ្រយ៉ាងខ្លាំងចំពោះការបង្កើតថ្មីនេះ ។ ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំបានដាក់ចេញនូវគោលការណ៍ណែនាំយ៉ាងច្បាស់ដល់មន្ទីរអប់រំទាំងអស់ស្តីអំពីចំនួនម៉ោងដែលត្រូវដាក់ឲ្យរៀនកម្មវិធីបំណិនជីវិតក្នុងសប្តាហ៍និមួយៗ ហើយក៏បានសង្កត់ធ្ងន់ដែរថាការបែងចែកម៉ោងនេះគឺជាតួនាទីរបស់យើងទាំងអស់គ្នា ។ ឯកឧត្តមណាត ប៊ុនរឿនក៏បានសុំឲ្យ IBEC រាយការណ៍អំពីបញ្ហាដែលជួបប្រទះក៏ដូចជាចំណុចជោគជ័យពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីបំណិនជីវិតក្នុងសន្និបាតអប់រំដែលនឹងត្រូវធ្វើឡើងក្នុងខែ មិនា ឆ្នាំ២០១២ ។

IBEC ក៏បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយឯកសារសាលាកុមារមេត្រី តាមសំណើសុំរបស់នាយកដ្ឋានបណ្តុះបណ្តាលគ្រូផងដែរ ហើយក៏បានទទួលការមកទស្សនកិច្ចតាមសាលារៀនពីដៃគូអភិវឌ្ឍផ្សេងៗដូចជា Sida និង UNICEF ជាមួយនឹងការរំពឹងទុកថាពួកគេនឹងជួយលើកម្ពស់ការអភិវឌ្ឍន៍ល្អទាំងនោះតាមរយៈគម្រោង ។

ការផ្លាស់ប្តូរសំខាន់មួយក្នុងគោលនយោបាយរបស់រដ្ឋាភិបាលអំពីការអប់រំបំណិនជីវិតគឺការធ្វើឲ្យមានការបង្រៀនបំណិនជីវិតជាចាំបាច់នៅមធ្យមសិក្សាទៅតាមគោលការណ៍ណែនាំរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នៅក្នុងគោលនយោបាយមុន ការអប់រំបំណិនជីវិតគឺធ្វើឡើងទៅតាមជ្រើស និងផ្អែកទៅលើធនធានគ្រូសហគមន៍សម្រាប់បង្រៀន ។ ប្រព័ន្ធអប់រំក្នុងសាលារៀននាពេលបច្ចុប្បន្នត្រូវបានប្តូរចេញពីគោលនយោបាននេះទាក់ទងការអប់រំបំណិនជីវិត ។ ការផ្លាស់ប្តូរនេះស្របពេលជាមួយនឹងការអនុវត្តសាកល្បងកម្មវិធីបំណិនជីវិតរបស់ IBEC ៕



*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*


*ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤* E-mail: worldedcam@worlded.org.kh

# សមាសភាគ១៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

ក្នុងការចាប់ផ្តើមឆ្នាំទី៣នេះ IBEC បានរៀបចំនូវការកសាងសមត្ថភាពជុំថ្មីមួយទៀតដល់អង្គការដៃគូក្នុងស្រុក និងមន្ត្រីរដ្ឋាភិបាល ។ អង្គការដៃគូក្នុងស្រុករបស់ IBEC ចំនួន៤បានបញ្ចប់ដំណើរការរៀបចំផែនការស្តង់ដារ និងផែនការបំប៉នរៀងៗខ្លួន ។ មានដៃគូចំនួន២គឺ KAPE និង BSDA បានខិតខំទៅរកការទទួលបាននូវវិញ្ញាបនបត្រទទួលស្គាល់ពី CCC ក្នុងការរំពឹងទុករបស់ KAPE ថាខ្លួននឹងទទួលបានវិញ្ញាបនបត្រនេះនៅក្នុងដើមត្រីមាសបន្ទាប់ ។ IBEC បានរៀបចំសិក្ខាសាលាកសាងសមត្ថភាពដ៏បើកទូលាយមួយដល់ដៃគូសម្រាប់ការធ្វើសវនកម្មដោយ RCA ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវគោលការណែនាំក្នុងការធ្វើលទ្ធកម្មរបស់ USAID ។

នៅក្នុងថ្នាក់ជាតិ IBEC ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំតាមរយៈការដឹកនាំរបស់ក្រុមពិគ្រោះយោបល់ (គណៈកម្មាធិការថ្នាក់ជាតិដែលមានតួនាទីមើលការខុសត្រូវគម្រោង) ។ សមាជិកថ្មីត្រូវបានបញ្ចូលក្នុងក្រុមពិគ្រោះយោបល់រួមទាំងតំណាងមកពីការិយាល័យ ICT ។ ក្នុងការរំកិលទៅមុខជាវិជ្ជមាន ក្រុមពិគ្រោះយោបល់ជាផ្លូវការបានយល់ព្រមអោយមានការចូលរួមពីនាយកដ្ឋាន៣ផ្សេងទៀតក្នុងការអនុវត្តសាកល្បងកម្មវិធីអប់រំបំណិនជីវិតរួមមាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ និងនាយកដ្ឋានមធ្យមសិក្សា ។

នៅថ្នាក់ខេត្ត ក្រុមពិគ្រោះយោបល់ថ្នាក់ខេត្តបានធ្វើការជួបប្រជុំតាមបណ្តាខេត្តនីមួយៗដើម្បីពិនិត្យឡើងវិញ និងធ្វើការអនុម័តទៅលើផែនការអភិវឌ្ឍរបស់សាលារៀនទាំងអស់ដែលទទួលបានទឹកប្រាក់វាប់សែនដុល្លាសហរដ្ឋអាមេរិក ក៏ដូចជាការណែនាំដល់ IBEC ទាក់ទងនឹងការជ្រើសរើសសាលារៀនថ្មីក្នុងការទទួលបាននូវបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ប្រព័ន្ធទឹក និងការជួសជុលបណ្ណាល័យ ។ ត្រីមាសនេះ IBEC ខ្លួនឯងបានបញ្ចប់នូវវគ្គបំប៉នជុំទី២ដល់ CEFACs ថ្មីចំនួន៦ឃុំ ដែលជាក្រុមបង្កើតឡើងដើម្បីជួយគាំទ្រ និងធ្វើឱ្យមាននិរន្តរភាពក្នុងសកម្មភាពអភិវឌ្ឍវិស័យអប់រំដល់សាលារៀនគោលដៅរបស់ IBEC តាមរយៈការផ្តល់ទុនបដិភាគ ។ IBEC បានដឹកនាំសាកល្បងដល់ឃុំចំនួន២ក្នុងខេត្តក្រចេះ និងសៀមរាបក្នុងការអនុវត្តសកម្មភាព ផ្តល់ទុនបដិភាគ ក្នុងនោះមានជិត៣០%នៃថវិកាសរុបដែលជំនួយដល់សាលារៀនបានមកពីទុនបដិភាគដែលប្រមូលបានក្នុងមូលដ្ឋាន ។ ជោគជ័យពីការសាកល្បងនេះនឹងជួយដល់គម្រោងក្នុងការកសាងឡើងនូវការអនុវត្តឱ្យកាន់តែប្រសើរសម្រាប់ឆ្នាំក្រោយនៅពេលដែលសាលារៀនក្នុងកម្រិតអភិវឌ្ឍជាច្រើននឹងចាប់ផ្តើមគាំទ្រដោយខ្លួនឯងតាមរយៈទុនបដិភាគដែលបានមកពី CEFACs ។

ដៃគូរបស់ IBEC គឺអង្គការ Equal Access បានបន្តផ្សព្វផ្សាយកម្មវិធីបំណិនជីវិតរបស់ខ្លួនតាមរយៈវិទ្យុដែលហៅថា *កម្មវិធីយើងអាចធ្វើបាន* និងសកម្មភាពចូលរួមរបស់សហគមន៍ ។ សកម្មភាពសំខាន់ៗជាច្រើន បានបញ្ចប់កាលពីត្រីមាសមុនរួមមាន ការផលិតកម្មវិធីវិទ្យុខ្លីៗចំនួន៤ និងការផ្សព្វផ្សាយ ការផលិត និងចែកចាយសៀវភៅតុក្កតាដែលមានភាពទាក់ទាញចំនួន២ប្រភេទ សកម្មភាពផ្សេងៗរបស់ក្រុមសិស្សយកព័ត៌មាន និងសកម្មភាពប្រជុំរបស់ក្រុមអ្នកស្តាប់ និងសន្ទនា ។ Equal Access បានរៀបចំផែនការ ការងាររបស់ខ្លួនសម្រាប់ត្រីមាសបន្ទាប់ដែលចាប់ផ្តើមពីខែមករាដល់ខែមីនា ឆ្នាំ២០១២ គឺជាត្រីមាសចុងក្រោយដែលអនុវត្តដោយ Equal Access ។ គួររំលឹកថា EA នឹងបិទការិយាល័យរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយនឹងប្តូរទៅជាអង្គការក្នុងស្រុកវិញ ដែលមានឈ្មោះថា Media One អង្គការក្នុងស្រុកមួយនេះនឹងបន្តធ្វើការជាមួយគម្រោង IBEC ក្នុងពេលដែល USAID មិនទាន់ចេញសេចក្តីសម្រេចនៅឡើយ ៕

## ការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ

Equal Access នៅកម្ពុជាបានធ្វើការផ្សព្វផ្សាយ *កម្មវិធីយើងអាចធ្វើបាន*តាមរយៈវិទ្យុជាមួយស្ថានីយវិទ្យុចំនួន២នៅក្នុងខេត្តកំពង់ចាម ដែលស្ថានីយនេះត្រូវបានប្រើចាប់តាំងពីកម្មវិធីបានផ្សព្វផ្សាយតាមរលកធាតុអាកាសជាលើកដំបូងក្នុងឆ្នាំ២០០៩មកម្លេះ ។ កម្មវិធីអប់រំខ្លីៗទាំងនោះជាទូទៅត្រូវបានផ្សព្វផ្សាយពីរលើកក្នុងមួយសប្តាហ៍តាមរយៈស្ថានីយនីមួយៗ ហើយម៉ោងសម្រាប់ផ្សព្វផ្សាយធ្វើឡើងជាដំណាក់ដូច្នេះសិស្សអាចស្តាប់អំឡុងពេលម៉ោងសិក្សា ឬក៏បន្ទាប់ពីម៉ោងសិក្សាផ្អែកទៅលើការចង់បានរបស់សិស្ស និងលោកគ្រូអ្នកគ្រូរបស់ពួកគេ ។ ក្នុងខែតុលា EA ចាប់ផ្តើមដំណើរការផលិតកម្មវិធីអប់រំបំណិនជីវិតតាមរយៈវិទ្យុថ្មីមួយទៀត ។ កម្មវិធីថ្មីនេះត្រូវបានបង្កើតឡើងបន្ទាប់ពីការពិនិត្យឡើងវិញទៅលើព័ត៌មានត្រឡប់ដែលបានមកពីអ្នកស្តាប់ ជាពិសេសព័ត៌មានត្រឡប់ដែលទទួលបានពីក្រុមអ្នកស្តាប់ដែលបានចូលរួមស្តាប់ចាប់តាំងពីពេលផ្សាយលើកដំបូង ។ EA ក៏បានធ្វើការលើកទឹកចិត្តដល់ក្រុមសិស្សយកព័ត៌មានផងដែរតាមរយៈការបង្កើតកម្មវិធីប្រកួតប្រជែងផ្សេងៗ គោលបំណងនៃកម្មវិធីប្រកួតប្រជែងនេះដើម្បីរកមើលថាតើក្រុមយកព័ត៌មានមួយណាដែលអាចផលិតកម្មវិធីព័ត៌មានដោយខ្លួនឯងបានល្អជាងគេ ។ អ្នកផលិតព័ត៌មានរបស់ EA ក៏បានថ្លែងនូវចំណាប់អារម្មណ៍របស់ខ្លួន និងធ្វើការលើកទឹកចិត្តដល់ក្រុមសិស្សយកព័ត៌មានដែលបានចូលរួមយ៉ាងច្រើនកុះករនៅក្នុងសកម្មភាពនេះ ។



EA កំពុងដំណើរការផលិតសៀវភៅតុក្កតាលេខ៥ និងល្បែងសិក្សា ដែលជាការបង្កើតឡើងក្នុងគោលបំណងអប់រំផង និងការកំសាន្តផង និងបានចែកចាយចាប់តាំងពីឆ្នាំ២០១០ មក ។ ការផលិតនោះបានបញ្ចប់រួចរាល់ ហើយកំពុងចាប់ផ្តើមបោះពុម្ព ចំណែកឯល្បែងសិក្សាកំពុងចិតក្នុងការរៀបចំលើកចុងក្រោយក្នុងចុងត្រីមាសនេះ ។ សៀវភៅតុក្កតានីមួយៗត្រូវបានដាក់ចំណងជើងបង្ហាញពី *កម្មវិធីវិទ្យុយើងអាចធ្វើបាន* ដែលផ្តោតលើសារសំខាន់ៗដែលដកស្រង់ចេញពីរឿងអប់រំខ្លីៗទាំងនោះ ។ សៀវភៅតុក្កតានោះក៏បានបញ្ចូលនូវលំហាត់ដែលឱ្យទាក់ទាញ ដែលបង្កើតឡើងដើម្បីឱ្យមានការចូលចិត្ត កំសាន្ត និងអប់រំយុវជន ។ បន្ថែមទៅលើការផ្សាយតាមវិទ្យុ EA ក៏បានបែងចែកថាសចម្លងរបស់កម្មវិធីវិទ្យុនីមួយៗដល់សាលារៀនចំនួន២០ក្នុងគោលដៅរបស់ KAPE ក្នុងខេត្តកំពង់ចាម ។ ថាសចម្លងជាផ្នែកមួយក្នុងការធ្វើឱ្យរីកដុះដាលនូវការសិក្សាតាមរយៈការស្តាប់នៅតាមបណ្ណាល័យសាលារៀននីមួយៗ ។ លំហាត់តាមរយៈថាសចម្លងធ្វើឱ្យការរៀនបានលឿនទៅមុខ និងមានសកម្មភាពក្នុងថ្នាក់រៀនច្រើនដែលទាក់ទងទៅនឹងគោលបំណងរបស់កម្មវិធី ។ អ្នកអត្ថាធិប្បាយបានចោទសំណួរទៅកាន់អ្នកស្តាប់ដើម្បីឱ្យមានការគិតដោយវិភាគអំពីប្រធានបទកម្មវិធី និងបំពេញនូវកិច្ចការខ្លីៗដែលអាចចែករំលែកដល់មិត្តរួមថ្នាក់ លោកគ្រូ អ្នកគ្រូ ឪពុកម្តាយ និងមិត្តភក្តិដទៃទៀត ៕

### ព័ត៌មានត្រឡប់ជាវិជ្ជមានពីអ្នកទទួលផល



"ចាប់ពីខ្ញុំបានក្លាយជាក្រុមសិស្សយកព័ត៌មាន ខ្ញុំមានឱកាសច្រើនក្នុងការជួបជាមួយមនុស្សថ្មី និងបានរៀនពីរបៀបធ្វើយ៉ាងណាដឹកនាំការសម្ភាសឱ្យបានល្អ និងពីរបៀបប្រមូលព័ត៌មានល្អៗ ។ ខ្ញុំបានដឹងថាខ្ញុំចាប់ផ្តើមមានទំនុកចិត្តលើខ្លួនឯងច្រើន និងមានភាពក្លាហានច្រើនជាងមុនផងដែរ ដូច្នេះខ្ញុំបានក្លាយជាសិស្សល្អ និងមានចំណេះដឹងច្រើនពីបញ្ហាសង្គម ។ ពីមុនខ្ញុំមិនមែនជាសិស្សរៀនពូកែទេ ហើយជាលទ្ធផលខ្ញុំពិតជាមិនសប្បាយចិត្តទេ ប៉ុន្តែនៅពេលដែលខ្ញុំធ្វើការសម្ភាសជាមួយសិស្សពូកែអំពីការសិក្សាបន្ថែមរបស់គេ គេបានចែករំលែកនូវព័ត៌មានសំខាន់ៗជាច្រើន ។ ខ្ញុំបានធ្វើតាមការណែនាំរបស់ពួកគេ ហើយជាលទ្ធផលពិន្ទុរបស់ខ្ញុំបានកើនឡើងមែន" ៕ ***សុភ័ក្រ្ត រៀនថ្នាក់ទី ១០***

"ខ្ញុំសង្កេតឃើញថាមិត្តភក្តិរបស់ខ្ញុំដែលជាក្រុមសិស្សយកព័ត៌មាន ចំណេះដឹងរបស់ពួកគេមានការកើនឡើង ដូចជាការរៀនពីរបៀបដឹកនាំការសម្ភាស និងប្រើប្រាស់ឧបករណ៍ថតសម្លេង និងពីរបៀបទំនាក់ទំនងជាមួយមនុស្សដទៃ ។ ខ្ញុំចង់ក្លាយជាអ្នកយកព័ត៌មាននៅថ្ងៃអនាគត នេះជាមូលហេតុដែលខ្ញុំសម្រេចចិត្តចូលរួមក្នុងក្រុមសិស្សយកព័ត៌មាននៅសាលារៀនរបស់ខ្ញុំ ។"



***មួយ អ៊ីម ថ្នាក់ទី៨***

# សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

## កម្មវិធីអាហារូបករណ៍

ត្រីមាសទី១នៃឆ្នាំសិក្សាគឺជាត្រីមាសដែលមានភាពមមាញឹកបំផុតសម្រាប់សមាសភាគទី២ ហើយឆ្នាំនេះក៏ដូចគ្នាដែរ ។ អំឡុងពេលនេះ IBEC ផ្តោតទៅលើសកម្មភាពចម្បងចំនួន៣ ៖ បន្តសហការជាមួយសាលារៀន និងសហគមន៍ដើម្បីរៀបចំធ្វើបុណ្យសាលារៀនក្នុងគោលបំណងបង្កើនការចូលរួមរបស់មាតាបិតាសិស្សក្នុងការអភិវឌ្ឍសាលារៀនក្នុងតំបន់របស់ពួកគេ សកម្មភាពសាលារៀនរកកុមារដើម្បីកំណត់រកកុមារដែលមិនបានចូលសាលារៀន និងការផ្តល់អាហារូបករណ៍ដល់សិស្សបឋម និងមធ្យមសិក្សា ។ ដោយផ្តោតលើបឋមសិក្សា IBEC បានធ្វើការជាមួយនាយកដ្ឋានបណ្តុះបណ្តាលគ្រូ និងក្រុមពិគ្រោះយោបល់ថ្នាក់ខេត្តដើម្បីកំណត់រកបេក្ខជនដែលមកពីតំបន់ដាច់ស្រយាលកំពុងខ្វះខាតគ្រូ ក្នុងការផ្តល់អាហារូបករណ៍ឲ្យពួកគេបានចូលរៀននៅសាលាគរុកោសល្យខេត្ត ។ នៅថ្នាក់បឋមសិក្សា IBEC បានផ្តល់អាហារូបករណ៍ដល់សិស្សជួបការលំបាកចំនួន ៤,១៧១នាក់ (ស្រី៥៧% ជនជាតិ៥%) ។ នៅមធ្យមសិក្សា IBEC បានបញ្ចូលសិស្សថ្នាក់ទី៧ដែលជួបការលំបាកខ្លាំងថ្មីចំនួន ៧៦៦នាក់ ជាសរុបទាំងសិស្សដែលបានជួយតាំងពីគម្រោងបានចាប់ផ្តើមមកមានចំនួន ១,៩៣៤នាក់ (ស្រី៦៩% ជនជាតិ៣%) ។ បេក្ខជនគរុសិស្សថ្មីចំនួន ១២០នាក់បានបញ្ចូលទៅក្នុងកម្មវិធីអាហារូបករណ៍រួចរាល់ហើយ IBEC ក្នុងពេលបច្ចុប្បន្នបានជួយគាំទ្រគរុសិស្សដែលកំពុងសិក្សានៅគរុកោសល្យសរុបចំនួន២៤០នាក់ ៕

## កញ្ចប់អំណោយសាលារៀនដែលដឹកនាំដោយអ្នកពាក់ព័ន្ធ

សកម្មភាពសំខាន់ក្នុងត្រីមាសនេះគឺការពិនិត្យឡើងវិញ និងអនុម័តផែនការអភិវឌ្ឍសាលារៀនទាំងអស់ដែលបានស្នើមកដោយកម្រងចំនួន៦១ និងសាលាមធ្យមចំនួន៩៨ ដើម្បីចូលរួមក្នុងគម្រោង ។ សាលារៀនត្រូវបានលើកទឹកចិត្តឲ្យកំណត់ជ្រើសរើសនូវបញ្ហាដែលជួបប្រទះដោយខ្លួនឯង បន្ទាប់មករៀបចំផែនការសកម្មភាពដោយដកចេញពីម៉ឺនុយសេវាកម្មដែលរៀបចំដោយ IBEC ដោយផ្អែកលើសមាសភាគទាំង៦របស់សាលាកុមារមេត្រីនៃក្រសួងអប់រំ ។ មានការសម្រេចចិត្តផ្សេងៗគ្នាក្នុងការជ្រើសរើសសកម្មភាពដោយសាលាដែលបានចូលរួមបង្ហាញពីភាពដឹកនាំដោយខ្លួនឯងទៅលើគម្រោង នេះគឺជាផលចំណេញមួយ ។ ក្នុងចំណោមកម្រងសាលាទាំងអស់មានការជ្រើសរើសសកម្មភាពខុសគ្នាចំនួន៥៣ប្រភេទដោយផ្អែកលើសមាសភាគទាំង៦របស់សាលាកុមារមេត្រីខណៈដែលមធ្យមសិក្សារើសយកសកម្មភាពចំនួន៦៤ផ្សេងៗគ្នា ។ ដោយមានការរើសយកសកម្មភាពផ្សេងៗក្នុងខេត្តទាំង៣ មន្ត្រីតាមមូលដ្ឋានបានបង្ហាញថាបឋមសិក្សាទាំងអស់នឹងអនុវត្តសកម្មភាពសរុបចំនួន១,៥០៣ ខណៈពេលដែលមធ្យមសិក្សានឹងអនុវត្តសកម្មភាពសរុបចំនួន៣,០៨៧ផ្សេងៗគ្នា ។ IBEC នឹងផ្តល់ថវិកាគាំទ្រផ្ទាល់ដល់សាលារៀនទាំងអស់ដើម្បីអនុវត្តសកម្មភាពទាំងនោះសរុបចំនួន ២៩០,៨៥០ ដុល្លាសហរដ្ឋអាមេរិក ៕



ជួយគ្នាក្នុងការរៀនសូត្រ៖ សិស្សធំបង្រៀនសិស្សតូចក្នុងខេត្តកំពង់ចាម

### ការផ្លាស់ប្តូរដែលមើលឃើញជាក់ស្តែង ៖ សហគមន៍ដែលជួបការលំបាក និងគ្រូបង្រៀនរបស់ខ្លួនបានទទួលជីវិតថ្មី



គ្រូសហគមន៍បង្រៀនក្រោមដើមឈើ



សាលារៀនថ្មីបានសាងសង់ឡើង



គ្រូចែកសម្ភារៈសិក្សាដែលទទួលបានពី USAID

ភូមិដាច់ស្រយាលជិតគ្នាចំនួន២ស្ថិតនៅកណ្តាលព្រៃក្នុងខេត្តក្រចេះ មានប្រជាជនរស់នៅចំនួន១៨៧គ្រួសារ និងមានកុមារចំនួន១១៤នាក់ កុមារទាំងនោះមិនមានលទ្ធភាពចូលសាលារៀនបានទេដោយសារតែហេតុផលថារដ្ឋាភិបាលមិនទាន់មានលទ្ធភាពផ្តល់ឲ្យសហគមន៍នេះនូវអគារសិក្សា ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ បុគ្គលិករបស់ IBEC ដែលមកពីអង្គការ WE និង KAPE បានធ្វើទស្សនកិច្ចដើម្បីប៉ាន់ស្មាននូវតម្រូវការក្នុងតំបន់នោះ មើលការបង្រៀនរបស់គ្រូសហគមន៍ដែលកំពុងបង្រៀនដោយគ្មានការបំប៉នផ្សេងៗ គ្មានសៀវភៅគោល និងសម្ភារៈឧបទ្ទេស ។ ដោយសារមានចំណាប់អារម្មណ៍ខ្លាំងពីសហគមន៍ក្នុងការបង្កើតសាលារៀន IBEC បានសម្រេចចិត្តជួយគាំទ្រសហគមន៍នេះ ។ ប្រជាជននៅក្នុងសហគមន៍ពួងដ៏ធំនេះបានសម្តែងនូវការកោតសរសើរ និងសប្បាយរីករាយដោយឮការសន្យារបស់ IBEC ហើយនិយាយថា USAID គឺជាម្ចាស់អំណោយតែមួយគត់ដែលមានចំណាប់អារម្មណ៍ជួយដល់ភូមិរបស់ពួកគេ ។

នៅដើមត្រីមាសនេះការសាងសង់សាលាបានបញ្ចប់រួចរាល់ ហើយការបង្រៀននាពេលបច្ចុប្បន្នកំពុងដំណើរការ ។ ឥឡូវនេះកុមារទាំងអស់ត្រូវបានផ្តល់ឲ្យនូវសម្ភារៈសិក្សាសម្រាប់ការសរសេរដូចជា ក្តារឆ្នួនសៀវភៅសរសេរ ខ្មៅដៃ ប៊ិច ក្តារខៀនចល័ត និងសៀវ ភៅគោលសម្រាប់គ្រប់មេរៀន ។ IBEC បានរៀបចំផែនការក្នុងការផ្តល់នូវប្រព័ន្ធទឹកស្អាត អណ្តូង និងធុងចម្រោះ ។ ដោយឃើញមានការប្រែប្រួលដ៏គួឲ្យកត់សម្គាល់ និងការវិនិយោគក្នុងវិស័យអប់រំដ៏សម្បើម ប្រធាន CEFACs បានសន្យាថានឹងព្យាយាមសុំឲ្យក្រសួងអប់រំចុះបញ្ជីសាលារៀននេះក្នុងបញ្ជីរដ្ឋ ដូច្នេះវានឹងមានការចាត់តាំងគ្រូរដ្ឋមកកាន់សាលារៀននេះក្នុងថ្ងៃអនាគត ៕

# សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

ក្នុងត្រីមាសនេះ IBEC បានបញ្ចប់សិក្ខាសាលាចំនួន៣ក្នុងចំណោមសិក្ខាសាលា៤ដែលជាផ្នែកមួយនៃវគ្គបំប៉នលើការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំរបស់ IBEC ។ វគ្គបំប៉ននេះនឹងឈានដល់ការផ្តល់វិញ្ញាបនបត្រដល់បុគ្គលិករដ្ឋបាលសាលារៀនទាំងអស់ដែលបានចូលរួម សិក្ខាសាលាបានចាប់ផ្តើមតាំងពីដើមត្រីមាសដែលមានបុគ្គលិករដ្ឋបាលចូលរួមសរុបចំនួន ៥៣៦នាក់ ។ សិក្ខាសាលានេះដឹកនាំដោយមន្ត្រីក្រសួងអប់រំចំនួន៣១នាក់ ដែលរើសចេញពីការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត និងផ្តោតទៅលើចំណុចសំខាន់ៗរួមទាំងគំនិតនៃការអប់រំភាពជាអ្នកដឹកនាំ ការបង្កើតគំនិតប្រចុយ និងការប្រើប្រាស់ចក្ខុវិស័យជាឧបករណ៍ធ្វើផែនការ ។ សិក្ខាសាលារយៈពេល៣ថ្ងៃនេះជាសិក្ខាសាលាឆ្លុះបញ្ចាំងដែលគ្រូឧទ្ទេសធ្វើឡើងដើម្បីកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយក្នុងការដឹកនាំសិក្ខាសាលា ក្នុងគោលបំណងដើម្បីធ្វើឲ្យប្រសើរឡើងនូវវគ្គបំប៉ននៅថ្ងៃអនាគត ។ IBEC បានរៀបចំទស្សនកិច្ចតាមដានទៅកាន់សាលារៀនទាំងអស់ដើម្បី ពិនិត្យមើលថាតើអ្នកចូលរួមក្នុងវគ្គបំប៉នការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំកំពុងដំណើរការបញ្ចប់ការងាររបស់ពួកគេយ៉ាងដូចម្តេច ដែលជាចំណុចសំខាន់មួយក្នុងការវាយតម្លៃដើម្បីឈានដល់ការផ្តល់វិញ្ញាបនបត្រដល់អ្នកចូលរួមវគ្គ ។ គ្រូឧទ្ទេស និង IBEC ខ្លួនឯងបានចុះទស្សនកិច្ចទៅកាន់សាលារៀនចំនួន២១៥នាក់ ដែលមានបុគ្គលិករដ្ឋបាលសាលារៀនសរុបចំនួន ៣៩៥នាក់ ។ ទោះជាយ៉ាងណាក៏ដោយ អន្តរាគមន៍របស់ IBEC ទាក់ទងទៅនឹងគណៈកម្មការទ្រទ្រង់សាលាត្រូវបានពន្យាពេលដោសារគ្រោះទឹកជំនន់ដែលជាបាតុភូតធម្មជាតិកើតឡើងជារៀងរាល់ឆ្នាំ និងប៉ះពាល់ដល់សាលារៀនជាច្រើនក្នុងអំឡុងត្រីមាសនេះ ។ សកម្មភាពសាលារៀនជួយគ្រួសារងាយរងគ្រោះក៏ត្រូវបានពន្យាពេលផងដែរដោយត្រូវរង់ចាំការអនុម័តពី USAID ក្នុងការធ្វើលទ្ធកម្មទៅលើសម្ភារៈកសិកម្មសម្រាប់សកម្មភាពនេះ ។ ទោះជាត្រូវពន្យាពេលយ៉ាងណាក៏ដោយ IBEC ក៏នៅតែអាចកំណត់រកគ្រួសារងាយរងគ្រោះថ្មីបានចំនួន៣០គ្រួសារដែលកូនរបស់ពួកគេកំពុងទទួលជំនួយអាហារូបករណ៍តាមរយៈកម្មវិធីសាលារៀនជួយគ្រួសារ របស់ IBEC។ គ្រួសារទាំងនោះនឹងទទួលជំនួយពីសាលារៀនដើម្បីអនុវត្តកម្មវិធីបំណិនជីវិតដែលកូនរបស់ពួកគេបានរៀននៅសាលា ជាងនេះទៅទៀតការអនុវត្តបំណិនតាមមូលដ្ឋានគឺអាចជួយគ្រួសារក្នុងការរកប្រាក់ចំណូលជាពិសេសតាមរយៈការប្រកបរបរកសិកម្មដូចជា ការចិញ្ចឹមមាន់ និងការដាំដំណាំ ៕

# សមាសភាគ៤៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

## ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន

ក្រុមបុគ្គលិក IT បានបញ្ចប់ការដំឡើងបន្ទប់កុំព្យូទ័រថ្មីចំនួន៤ក្នុងត្រីមាសនេះ ដែលជាផ្នែកមួយនៃផែនការក្នុងឆ្នាំទី៣ក្នុងការដំឡើងបន្ទប់កុំព្យូទ័រសរុបចំនួន៨ (២បន្ទប់ជាថវិកាបដិភាគពីមូលនិធិ Oaktree) ក្នុងនោះ៥បន្ទប់ត្រូវបានដំឡើងក្នុងខេត្តកំពង់ចាម និង៣បន្ទប់ទៀតដំឡើងនៅក្នុងខេត្តសៀមរាប ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យមានការចូលរួមពីមន្ទីរអប់រំខេត្តក្នុងដំណើរការនេះ IBEC បានធ្វើការជាមួយក្រុមពិគ្រោះយោបល់ថ្នាក់ខេត្តដើម្បីកំណត់ និងជ្រើសរើសសាលារៀនដែលត្រូវទទួលបានបន្ទប់កុំព្យូទ័រ ។ សរុបទាំងបន្ទប់កុំព្យូទ័រដែលបានផ្តល់តាំងពីគម្រោងបានចាប់ផ្តើមមក USAID បានជួយគាំទ្របន្ទប់កុំព្យូទ័រសរុបចំនួន៣៤ហើយរហូតដល់ចុងឆ្នាំនេះ ។ តាមការអនុវត្តកម្មវិធី បន្ទប់កុំព្យូទ័រដែលបានដំឡើងរួចរាល់ហើយក្រុមបុគ្គលិក IT បានផ្តល់វគ្គបំប៉នទៅលើការប្រើប្រាស់ទៅតាមមុខវិជ្ជា លោកគ្រូអ្នកគ្រូបានចំណាយពេលវេលាបន្ថែមដើម្បីបង្រៀនកុំព្យូទ័រដល់សិស្ស ។ ឆ្នាំនេះគ្រូ IT សរុបចំនួន២៤នាក់ត្រូវបានជ្រើសរើសដើម្បីទទួលវគ្គបំប៉ន ។ IBEC ក៏បានធ្វើកំណែរទៅលើឯកសារទស្សនៈទានស្តីអំពីសាលាធនធានផ្នែកបច្ចេកវិទ្យា និងបានដាក់សំណើនេះជូនក្រសួងអប់រំ ។ ការស្នើឡើក្នុងការបង្កើតសាលាធនធានផ្នែកបច្ចេកវិទ្យានេះគឺធ្វើឡើងដើម្បីអភិវឌ្ឍភាពជាដៃគូរវាងឯកជន និងរដ្ឋជាមួយក្រុមហ៊ុន Microsoft ក្រសួងអប់រំបាននឹងកំពុងពិនិត្យទៅលើសំណើសុំនេះដើម្បីឲ្យស្របទៅនឹងគោលនយោបាយ ICT របស់ក្រសួងអប់រំ និងសន្យាថាផ្តល់ការឆ្លើយតបទៅលើសំណើរក្នុងពេលឆាប់ៗ ។

ឆ្ពោះទៅរកការបញ្ចប់នៃត្រីមាសចុងក្រោយ IBEC ផ្ទាល់បានចូលរួមក្នុងកិច្ចប្រជុំស្តីអំពីភាពទាក់ទងគ្នាក្នុងតំបន់អាស៊ី សម្រាប់ការអប់រំ និងអភិវឌ្ឍនៅក្នុងទីក្រុងហាណូយប្រទេសវៀតណាម ប្រធានកម្មវិធី IT របស់ IBEC បានធ្វើបទបង្ហាញអំពីភាពជោគជ័យនៃការបង្កើតបន្ទប់ IT ដែលមាននិរន្តរភាពរបស់ IBEC ។ វាបង្ហាញឲ្យឃើញនូវឱកាសដ៏អស្ចារ្យមួយក្នុងការបង្ហាញដល់អន្តរជាតិអំពីភាពជោគជ័យក្នុងការផ្តល់ការប្រើប្រាស់ប្រព័ន្ធ IT ដល់សាលារៀននៅក្នុងប្រទេសកម្ពុជារបស់ IBEC ៕



បន្ទប់កុំព្យូទ័រថ្មីតម្លើងក្នុងខេត្តកំពង់ចាម៖ គម្រោងបានបង្កើតគំរូតុកុំព្យូទ័រថ្មីដើម្បីការពារទឹកជំនន់ជាពិសេសចំពោះសាលាដែលងាយរងគ្រោះ

## ការបណ្តុះបណ្តាលគ្រូ

ក្នុងត្រីមាសនេះ IBEC បានដឹកនាំសិក្ខាសាលាបំប៉នដែលមានគ្រូជាច្រើនបានចូលរួមទៅលើប្រធានបទជាច្រើនដែលទាក់ទងទៅនឹងសកម្មភាពសាលាកុមារមេត្រី ក្លឹបមុខវិជ្ជា ក្លឹបវិទ្យាសាស្ត្រ និង ការជួយគ្រូ ។ មានគ្រូថ្មីមកពីបឋមសិក្សាជាច្រើនក្នុងខេត្តសៀមរាបបានចូលរួមក្នុងសិក្ខាសាលាស្តីពីកម្មវិធីសាលាកុមារមេត្រីនេះ (សរុប៩៣នាក់/ស្រី៥៤នាក់) និងមានគ្រូផ្សេងទៀតមកពីមធ្យមសិក្សា (សរុប៧១/ស្រី៤២) ។ គ្រូដែលបានចូលរួមក្នុងវគ្គបំប៉នមុនៗក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះត្រូវបានតម្រូវឲ្យចូលរួមវគ្គបំប៉នរំលឹកឡើងវិញក្នុងត្រីមាសបន្ទាប់ ។ គោលបំណងក្នុងវគ្គបំប៉ននេះគឺដើម្បីធ្វើការកសាងសមត្ថភាពគ្រូក្នុងគោលការណ៍ឲ្យសមស្របទៅនឹងកម្មវិធីសាលាកុមារមេត្រី ។ មាតិការក្នុងការបំប៉នជាក់ស្តែងគឺផ្តោតទៅលើ (i) ការបង្កើតបន្ទប់មុខវិជ្ជា និងការគ្រប់គ្រង (ii) បំណិនសួរសំណួរ (iii) ការអភិវឌ្ឍល្បែងសិក្សា (iv) របៀបកែលម្អបរិស្ថានថ្នាក់រៀន (v) អភិវឌ្ឍជំនាញអាន និងសរសេរ (vi) ការវាយតម្លៃសិស្ស (vii) ការបង្រៀនដោយឆ្លុះបញ្ចាំង និង (viii) ការវាយតម្លៃដោយខ្លួនឯង ។ សិក្ខាសាលាបំប៉ននេះបានប្រើប្រាស់ឯកសារប្រសិទ្ធភាពក្នុងការបង្រៀន និងរៀនដែលបង្កើតឡើងដោយក្រសួងអប់រំ បុគ្គលិក IBEC ជាមួយនឹងដៃគូក្រសួងរបស់ខ្លួនដឹកនាំការទស្សនកិច្ចតាមដានទៅកាន់កម្រងសាលាជាច្រើនដើម្បីផ្តល់នូវការជួយគាំទ្របច្ចេកទេសបន្ថែម និងធ្វើការចែកចាយសម្ភារៈឧបទ្ទេស ។

សមាសភាគនេះក៏បានបញ្ចប់ផងដែរនូវការបំប៉នបន្ថែមដល់គ្រូចំនួន ៥១នាក់ (ស្រី២០នាក់) ក្នុងការបង្កើតក្លឹបមុខវិជ្ជាដើម្បីជួយសិស្សក្នុងការបង្កើតនូវចំណាប់អារម្មណ៍ពិសេសដូចជាប្រវត្តិសាស្ត្រ និពន្ធ និងវិទ្យាសាស្ត្រ។ ក្លឹបចំនួន៩៣មកពី៥៣សាលារៀនបានដឹកនាំដោយសិស្សខ្លួនឯង ប៉ុន្តែត្រូវបានទទួលការសម្របសម្រួលពីគ្រូ ។ IBEC ក៏បានបញ្ចប់សិក្ខាសាលារយៈពេល៤ថ្ងៃផងដែរស្តីអំពីការបង្កើតឯកសារពិសោធន៍វិទ្យាសាស្ត្រសម្រាប់គ្រូចំនួន៣៧នាក់ដោយប្រើសៀវភៅធនធានដែលអភិវឌ្ឍដោយគម្រោងកាលពីឆ្នាំមុន សិក្ខាសាលានេះធ្វើឡើងដើម្បីផ្តល់ការបំប៉នគរុកោសល្យដល់គ្រូវិទ្យាសាស្ត្រក្នុងសាលាដែលមានបន្ទប់ពិសោធន៍ថ្មី ជាពិសេសដើម្បីប្តូរពីការសិក្សាបែបទ្រឹស្តីទៅរកការសិក្សាបែបអនុវត្តផ្ទាល់ ។ ដោយស្ថានភាពខ្វះគ្រូនៅតែបន្តយ៉ាងធ្ងន់ធ្ងរ បុគ្គលិក IBEC បានធ្វើការជ្រើសរើស និងបំប៉នគ្រូសហគមន៍ថ្មីចំនួន៦៣នាក់ដែលនឹងត្រូវជួយដល់សាលារៀន និងតំបន់ដែលទទួលការប៉ះពាល់ធ្ងន់ធ្ងរ ។ ក្នុងករណីនៃការប្រើប្រាស់ បណ្តាញប្រសិទ្ធិភាព IBEC ទើបនឹងបានសហការភាពជាដៃគូជាមួយអង្គការ See Beyond Borders ដែលនឹងត្រូវធ្វើការជាមួយគម្រោងដើម្បីលើកកម្ពស់បំណិនរៀនចំនួនក្នុងចំណោមគ្រូបឋមសិក្សាក៏ដូចជាតាមដាននូវឥរិយាបទរបស់ក្រុមជួយគាំទ្របច្ចេទេស ។ ការធ្វើតេសជាមូលដ្ឋានទៅកាន់ចំនួនសាលារៀនពីរ ឬបីក្នុងគោលបំណងតាមដានទៅលើការផ្លាស់ប្តូរ នូវបំណិនរៀនចំនួនដើម្បីបង្ហាញលទ្ធផលពីកញ្ចប់គណិតវិទ្យា និងគាំទ្រដោយ SBB ៕



ការសិក្សាដោយប្រសិទ្ធភាពគឺជាឫសគល់៖ គ្រូកុមារមេត្រីមធ្យមសិក្សាក្នុងខេត្តក្រចេះពិនិត្យមើលការងារក្រុមក្នុងថ្នាក់របស់គាត់

## ក្របខណ្ឌកម្មវិធីបំណិនជីវិត

ចំណុចដែលផ្តោតសំខាន់របស់ក្រុមបំណិនជីវិតក្នុងត្រីមាសនេះ គឺការអនុវត្តកម្មវិធីបំណិនជីវិតសាកល្បងនៅមធ្យមសិក្សា ។ គ្រប់សកម្មភាពទាំងអស់ក្នុងឆ្នាំទី៣កំពុងដំណើរការក្នុងត្រីមាសនេះ រួមទាំងការបង្កើតនូវយុទ្ធសាស្ត្រតាមដានវាយតម្លៃ ដែលបង្ហាញអំពីភាពជិតបានសម្រេច និងត្រូវប្រើឧបករណ៍ចំនួន១៤ក្នុងការប្រមូលទិន្នន័យ ។ យុទ្ធសាស្ត្រនេះនឹងអនុវត្តក្នុងកិច្ចសហការណ៍ជាមួយនឹងតំណាងមកពីនាយកដ្ឋានសំខាន់ៗ៣រួមមាន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យសិក្សា និងនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ IBEC បានបែងចែកសៀវភៅបំណិនជីវិត ផ្ទាំងប៉ូស្ទ័រ និងឯកសារសិស្សជាច្រើនទៅកាន់សាលារៀនគោលដៅក្នុងដើមត្រីមាសនេះ ។ ជារួម IBEC បានបែងចែងកម្មវិធីសិក្សាទៅកាន់សាលារៀនគោលដៅចំនួន ៧៣,៨៦៧ច្បាប់ គម្រោងបានរាយការណ៍ទៅលើសកម្មភាពសំខាន់ៗរបស់ខេត្តទាំង៣ ក្នុងការកើនឡើងនូវសកម្មភាពបំណិនជីវិតដែលកើតឡើងនៅមធ្យមសិក្សា ។ ក្នុងចំណោមសាលារៀនចូលរួមចំនួន៩៦មានការអនុវត្តកម្មវិធីបំណិនជីវិតចំនួន៧៨៤សកម្មភាពនៅមធ្យមសិក្សា និង១៤៨សកម្មភាពនៅបឋមសិក្សា ។ សកម្មភាពបំណិនជីវិតនៅក្នុងសាលារៀនគឺជាការចូលរួមក្នុងដំណើរការរៀនលើគ្រប់វិស័យរួមទាំង (i) ការសិក្សាពាក់ព័ន្ធនឹងបញ្ហាសង្គម (ii) ការសិក្សាពីជំនួញ និងសេដ្ឋកិច្ច និង (iii) ការអនុវត្តបំណិនជីវិតអាជីពងាយ ។ បុគ្គលិក IBEC បានរាយការណ៍ថាប្រធានបទបំណិនជីវិតមួយចំនួនមានការពេញនិយមសម្រាប់សាលារៀនមួយចំនួនដោយមាន ៦៦% ជ្រើសរើសប្រធានបទស្តីអំពីការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ៥៣% ជ្រើសរើសជំនាញគ្រប់គ្រងប្រាក់ និង ៥៥% ជ្រើសរើសសួនជីវៈ ។ សាលារៀនភាគច្រើនជ្រើសរើសយ៉ាងតិចពីរប្រធានបទ ហើយសាលារៀនផ្សេងទៀតជ្រើសរើសច្រើនជាងនេះ ។ ប្រធានបទពីរប្រភេទខាងដើមត្រូវបានពេញនិយមយ៉ាងខ្លាំងក្នុងត្រីមាសនេះ ។ ទាក់ទងនឹងចំនួនម៉ោងសរុបដែលបង្រៀនបំណិនជីវិត (ប្រហែលពី ៣៦% ទៅ ៣៩% បានបង្រៀនបំណិនជីវិតតរៀងគ្នា) ។ ក្នុងការពង្រឹងការអនុវត្តកម្មវិធី បុគ្គលិក IBEC បានរៀបចំសិក្ខាសាលារយៈពេលពីរថ្ងៃដែលមានគ្រូចូលរួមចំនួន ៨៣៧នាក់ (ស្រី៣១៥នាក់)ពីសាលារៀនគោលដៅ ។ វគ្គសិក្ខាសាលារំលឹកឡើងវិញស្តីអំពីការអប់រំបំណិនជីវិតនេះបានផ្តោតទៅលើគំនិតមួយចំនួនដូចជា ផែនទីគំនិត គោលការណ៍សិក្សាបែបសហការ ការចូលរួមពីសហគមន៍ និងការពិភាក្សាលើប្រធានបទជាក់លាក់អំពីបំណិនជីវិត ៕